J BMA｜ការប្រឡងសមាគមថែទាំអគារជប៉ុន (JBMA)

## ស្តីអំពីការប្រលងវាយតម្លៃពលករជំនាញកម្រិត1វិស័យសម្អាតអគារ

នេះគឺជាការប្រឡងជំនាញដែលប្រឡងដោយអ្នកដែលចង់ទៅធ្វើការនៅប្រទេសជប៉ុនក្នុងស្ថានភាពស្នាក់នៅក្នុងនាមជា "ពលករជំនាញកម្រិត 1 (ការសម្អាតអគារ)"។ពិនិត្យមើលជំនាញ និងចំណេះដឹងទាក់ទងនឹងការសម្អាតអគារ។

## សិទ្ធិនៃការប្រឡង

- មានអាយុចាប់ពី17ឆ្នាំឡើងទៅនៅថ្ងៃប្រឡង។ ប៉ុន្តែ សម្រាប់ជនជាតិឥណ្ឌូនេស៊ីត្រូវតែមានអាយុចាប់ពី 18 ឆ្នាំឡើងទៅនៅថ្ងៃប្រឡង។
- អ្នកធ្វើការប្រឡងនៅប្រទេសជប៉ុន ត្រូវតែមានស្ថានភាពស្នាក់នៅក្នុងកំឡុងពេលមានសុពលភាព។

## ខ្លឹមសារការប្រឡងនិងពេលវេលាប្រឡង

ការប្រឡងរួមមានការប្រឡងសរសេរ និងការប្រឡងអនុវត្ត។ ទាំងអស់ធ្វើដោយភាសាជប៉ុន។

ការប្រឡងសរសេរៈចំណួនសំណួរ 20សំណួរ (ប្រឡងជាប់គឺលើសពី60%នៃពិន្ទុពេញ) ពេលវេលាប្រឡង20 នាទី

ការប្រឡងអនុវត្តៈចំណួនសំណួរ30សំណួរ (ប្រឡងជាប់គឺលើសពី60%នៃពិន្ទុពេញ)ពេលវេលាប្រឡង30 នាទី

បន្ថែមពីលើការប្រឡងសរុបរយៈពេល 50 នាទី អ្នកក៏ត្រូវចំណាយពេល 10 នាទីផងដែរក្នុងការយល់ព្រមលើកិច្ចព្រមព្រៀងរក្សាការសម្ងាត់ ការបង្ហាត់បង្ហាញ និងការស្ទង់មតិ។

## តម្លៃនៃការប្រឡង

ករណីធ្វើការប្រឡងនៅប្រទេសជប៉ុនៈ4,400យ៉េន (រួមបញ្ចូលពន្ធប្រើប្រាស់ 10%)

ករណីធ្វើការប្រឡងនៅប្រទេសក្រៅពីជប៉ុនៈ30ដុលា

## របៀបចុះឈ្មោះតាមអ៊ីនធឺណិត ការកក់ ～ការប្រឡង

ជំហានទី **1៖ ការចុះឈ្មោះអ្នកប្រើប្រាស់ថ្មី (ចុះឈ្មោះគណនី)**

ដើម្បីធ្វើការប្រឡងវាយតម្លៃពលករជំនាញកម្រិត 1 ការសម្អាតអគារជាមួយ Pearson VUE

ចាំបាច់ត្រូវចុះឈ្មោះគណនីអ្នកប្រើប្រាស់។សូមធ្វើការចុច "បង្កើតគណនី"

ហើយធ្វើតាមការណែនាំនៅលើអេក្រង់ដើម្បីចុះឈ្មោះអ្នកប្រើប្រាស់។សម្រាប់អ្នកដែលមានគណ នីស្រាប់ សូមបន្តទៅជំហានទី2។

*សូមប្រុងប្រយ័ត្នប្រសិនបើឈ្មោះដែលបានចុះឈ្មោះខុសពីឈ្មោះនៅលើឯកសារបញ្ជាក់សាមីខ្លួនដែលអ្នកបង្ហាញនៅមណ្ឌលប្រឡងនៅថ្ងៃប្រឡងនោះ អ្នកនឹងមិនត្រូវបានអនុញ្ញាតឱ្យធ្វើការប្រឡងទេ។

## ប្រុងប្រយ័ត្ន

អាចធ្វើការដាក់ពាក្យបានរហូតដល់ថ្ងៃទី 31 ខែមីនា ឆ្នាំ 2026។ បន្ទាប់ពីថ្ងៃទី 1 ខែមេសា ឆ្នាំ 2026 អាចធ្វើការកក់នៅក្នុងប្រព័ន្ធបាន ប៉ុន្តែសូមកុំធ្វើការកក់។

ជំហានទី **2៖ ការកក់ការប្រឡង**

សូមបញ្ចូលឈ្មោះអ្នកប្រើប្រាស់ និងលេខសម្ងាត់ដែលអ្នកបានចុះឈ្មោះក្នុងជំហានទី 1 ដើម្បីកក់ការប្រឡង។

*សម្រាប់អ្នក មានប័ណ្ណទូទាត់ សូមចុច "បន្ថែមប័ណ្ណទូទាត់ ឬលេខកូដប្រូម៉ូសិន " នៅលើអេក្រង់ដែលអ្នកបញ្ចូលព័ត៌មានការទូទាត់ និងព័ត៌មានវិក្កយបត្រ ហើយបញ្ចូលលេខប័ណ្ណទូទាត់ដែលអ្នកមាន សូមបញ្ចប់ការកក់បន្ទាប់ពីចុច"ប្រើប្រាស់" ។

*បន្ទាប់ពីបញ្ចប់ការកក់ នឹងទទួលបានអ៊ីមែលបញ្ជាក់ការកក់

**រយៈពេល**ផុតកំណត់នៃការកក់ ការផ្លាស់ប្តូរការកក់ **រយៈពេល**ផុតកំណត់នៃការលុបចោល

- **រយៈពេល**ផុតកំណត់នៃការកក់៖ ដល់ម៉ោង 11:59 យប់មុនថ្ងៃប្រឡងដែលអ្នកចង់ប្រឡង
- **រយៈពេល**ផុតកំណត់នៃការ **ផ្លាស់ប្តូរ** លុបចោល៖ រហូតដល់ 24 ម៉ោងមុនកាលបរិច្ឆេទកក់បច្ចុប្បន្ន

**ចំណាំ៖** រយៈពេលផុតកំណត់នីមួយៗគឺជារយៈពេលផុតកំណត់នៅលើគេហទំព័រកក់តាមអ៊ីនធឺណិត។ នៅពេលធ្វើការកក់ ផ្លាស់ប្តូរការកក់ ឬលុបចោលការកក់តាមរយៈសេវាកម្មអតិថិជន អ្នកត្រូវតែបញ្ចប់ក្នុងរយៈពេលផុតកំណត់នីមួយៗ និងក្នុងអំឡុងពេលម៉ោងការងារសេវាកម្មអតិថិជន។ ការកក់ទុកមិនអាចផ្លាស់ប្តូរ ឬលុបចោលបានទេ បន្ទាប់ពីរយៈពេលផុតកំណត់។

**វិធីបង់ប្រាក់**

វិធីបង់ប្រាក់ថ្លៃប្រឡងគឺមានតែដោយកាតក្រេឌីតនិងប័ណ្ណទូទាត់តែប៉ុណ្ណោះ។

- កាតក្រេឌីត
  អាចប្រើប្រាស់កាត VISA、Master、JCB、AMEX
- ប័ណ្ណទូទាត់ជាមុន
  ប្រសិនបើការបង់ប្រាក់ថ្លៃប្រលងត្រូវទទួលបន្ទុកដោយខាងក្រុមហ៊ុននិងសាលា អាចប្រើប្រាស់ប័ណ្ណទូទាត់ ជាមុន។ប៉ុន្តែ ចំណួនទិញអប្បបរមាគឺចាប់ពី 10 ការប្រឡង (10 នាក់) ឡើងទៅ។ សម្រាប់ព័ត៌មានលម្អិតពីរបៀបទិញប័ណ្ណទូទាត់ជាមុន សូមធ្វើការបញ្ជាក់តាមរយៈតំណភ្ជាប់ខាងក្រោម។ បន្ទាប់ ពី ទិញ ប័ណ្ណ ទូទាត់ជាមុនហើយ សូម ចែក លេខ ប័ណ្ណ ជូនដល់ បេក្ខជនប្រឡងនីមួយៗ។
  (ករណីធ្វើការប្រឡងនៅប្រទេសជប៉ុន) កន្លែងលក់ប័ណ្ណ ទូទាត់ *ចំណួនទិញអប្បបរមា៖ សម្រាប់10ការប្រឡងឡើង
  (ករណីធ្វើការប្រឡងក្រៅពីប្រទេសជប៉ុន) Purchase Vouchers *ចំណួនទិញអប្បបរមា៖ សម្រាប់1ការប្រឡងឡើង

ជំហានទី **3៖ ការរៀបចំសម្រាប់ការប្រឡង**

សូមពិនិត្យមើលទំព័រខាងក្រោមសម្រាប់ការរៀបចំ និងនីតិវិធីសម្រាប់ថ្ងៃប្រឡង។

- ចំណុចបញ្ជាក់មុនការប្រឡង
  ចំណុចបញ្ជាក់មុនការប្រឡង(ភាសាជប៉ុន)
  Helpful resources for test-takers（English）
- ដំណើរការទូទៅនៅមណ្ឌលប្រឡងនៅថ្ងៃប្រឡង (វីដេអូ)
  និតិវិធីនៃការប្រឡង(ភាសាជប៉ុន)
  What to expect when testing with Pearson VUE（English）
- ការប្រឡងសាកល្បង CBT
  ការប្រឡងសាកល្បង(ភាសាជប៉ុន)

ជំហានទី **4៖ ការប្រឡង**

**ពេលវេលាមកកន្លែងប្រឡង**

នៅថ្ងៃប្រឡង សូមទៅដល់មជ្ឈមណ្ឌលប្រឡង យ៉ាងហោចណាស់ 15 នាទីមុនពេលចាប់ផ្តើមការប្រឡង ដើម្បីធ្វើដំណើរការចុះឈ្មោះ។ប្រសិនបើអ្នកមកយឺត នឹងមិនត្រូវបានអនុញ្ញាតឱ្យចូលប្រឡងទេ ហើយថ្លៃប្រឡង នឹងមិនត្រូវបានសងវិញដែរ។

**របស់យកមក**

នៅពេលចុះឈ្មោះ**ត្រូវចាំបាច់បង្ហាញឯកសារបញ្ជាក់សាម៉ីខ្លួន 1** ដែលមានសុពលភាព។ សូមធ្វើការបញ្ជាក់ទំព័រ ខាងក្រោម សម្រាប់ព័តមានលំអិត។ប្រសិនបើ "ឈ្មោះនៅលើការកក់ " និង "ឈ្មោះនៅលើឯកសារបញ្ជាក់សាម៉ីខ្លួន " ខុសគ្នា អ្នកនឹងមិនត្រូវបានអនុញ្ញាតឱ្យប្រឡងទេ។ ប្រសិនបើអ្នកមិនត្រូវបានអនុញ្ញាតឱ្យប្រឡងដោយសារតែឈ្មោះមិនត្រូវគ្នា ថ្លៃប្រឡងរបស់អ្នកនឹងមិនត្រូវបាន សងវិញទេ។

(ករណីប្រលងនៅប្រទេសជប៉ុន) ស្តីអំពីឯកសារបញ្ជាក់សាម៉ីខ្លួន *ករណីប្រឡងនៅប្រទេសជប៉ុន សូមធ្វើការរយក លិខិតឆ្លងដែនមក។

(ករណីប្រឡងនៅក្រៅពីប្រទេសជប៉ុន) Global ID Policy 1 * ករណីមានលិខិតឆ្លងដែនសូមធ្វើការរយក លិខិតឆ្លងដែនមក។

មិនអាចយករបស់របរផ្ទាល់ខ្លួនចូលទៅក្នុង បន្ទប់ ប្រឡងបានទេ។ សូម ណែនាំ ថា អ្នក មិន គួរយករបស់របរ ដែល មិន ចាំបាច់ សម្រាប់ការ ប្រឡងមកនោះទេ។

ក្រដាសកត់ត្រាពណ៌ស និងប៊ិច (ប៊ិចទឹកដែលស្លួតរហ័ស) នឹងត្រូវបានផ្តល់ជូននៅតុចុះឈ្មោះ ដូច្នេះអ្នកអាចកត់ត្រាក្នុងអំឡុងពេលប្រឡងបាន។ បន្ទាប់ពីការប្រឡងរួច ក្រដាសកត់ត្រាពណ៌ស និងប៊ិចនឹងត្រូវប្រមូល។




**ការយល់ព្រមនឹងកិច្ចព្រមព្រៀងរក្សាការសម្ងាត់(NDA)**

មុនពេលអ្នកចាប់ផ្តើមការប្រឡងនៅមជ្ឈមណ្ឌលប្រឡង អ្នកនឹងត្រូវតម្រូវឱ្យធ្វើការយល់ព្រមនឹងកិច្ចព្រមព្រៀងរក្សាការសម្ងាត់ (NDA)។ NDA គឺជាកិច្ចព្រមព្រៀងចម្បងមួយក្នុងការយល់ព្រមមិនបង្ហាញសំណួរ ឬចម្លើយទៅកាន់ភាគីទីបី។ប្រសិនបើអ្នកមិនយល់ព្រមទេ អ្នកនឹងមិនអាចចាប់ផ្តើមការប្រឡងបានទេ។ ហើយ ប្រសិនបើមិនបានប្រឡងដោយសារមិន យល់ព្រមក៍ដោយ នោះ ថ្លៃ ប្រឡង របស់ អ្នក នឹង មិន ត្រូវ សង វិញ ទេ។ ប្រសិនបើបន្ទាប់ពីការប្រឡង ត្រូវបានគេរកឃើញថាអ្នកបានចូលរួមក្នុងការប្រព្រឹត្តចំណុចដែលត្រូវបានហាមឃាត់ដែលបំពានលើលក្ខខណ្ឌនៃកិច្ចព្រមព្រៀង ស្ថាប័នវិញ្ញាបនប័ត្រអាចដកហូតវិញ្ញាបនប័ត្ររបស់អ្នក ឬហាមឃាត់អ្នកមិនឱ្យប្រឡងនៅពេលអនាគត។

ជំហានទី **5៖ លទ្ធផលការប្រឡង**

លទ្ធផលការប្រឡង នឹងជូនដំណឹងតាមវិធីសាស្រ្ត2ខាងក្រោម

- របាយការណ៍ពិន្ទុ
  ភ្លាមៗបន្ទាប់ពីការប្រឡង នៅមជ្ឈមណ្ឌលប្រឡងនឹងព្រីនចេញរបាយការណ៍ពិន្ទុ (ជាប់/ធ្លាក់)ហើយអោយទៅអ្នក។អ្នកក៍អាចមើលរបាយការណ៍ពិន្ទុដូចគ្នានៅលើទំព័រអ្នកប្រើប្រាស់ Pearson VUE របស់អ្នកនៅពេលក្រោយ។
  **ចំណាំ៖** របាយការណ៍ពិន្ទុមិនមែនវិញ្ញាបនបត្រប្រឡងជាប់ទេ។
- វិញ្ញាបនបត្រប្រឡងជាប់
  បន្ទាប់ពីត្រូវបានសម្រេចថាកិច្ចសន្យាការងារនឹងត្រូវបានធ្វើរវាងបេក្ខជនប្រឡងជាប់ និងអង្គការទទួលយក

សមាគមថែទាំអគារជប៉ុននឹងចេញវិញ្ញាបនបត្រប្រឡងជាប់ ទៅឱ្យស្ថាប័នទទួលយកបន្ទាប់ពីបេក្ខជនបានដាក់ពាក្យស្នើសុំ និងបង់ថ្លៃចេញប័ណ្ណចំនួន 11,000 យ៉េន (រួមទាំងពន្ធប្រើប្រាស់ 10%)។

## ចំណុចប្រុងប្រយ័ត្ន

អ្នក ដែលមាន បំណង ប្រឡងឬ អ្នកដែលបានប្រឡង ដោយ មធ្យោបាយ និងសកម្មភាពមិនត្រឹ មត្រូវ នឹង ត្រូវ ហាមឃាត់ មិន ឲ្យ ប្រឡង រហូត ដល់ 5 ឆ្នាំ។

ប្រសិនបើអ្នកប្រឡងជាប់ឬ អ្នកដែលប្រឡង ដោយមធ្យោបាយ និងសកម្មភាពមិនត្រឹ មត្រូវ នោះការប្រឡងរបស់អ្នកនឹងត្រូវបានដកហូត ហើយយើងនឹងស្នើសុំលិខិតបញ្ជាក់ការប្រឡងជាប់របស់អ្នកត្រឡប់មកវិញ។ សូមចំណាំថាថ្លៃប្រឡង និងថ្លៃចេញវិញ្ញាបនបត្របញ្ជាក់ការប្រឡងជាប់គឺមិនសងវិញបានទេ។

## ព័ត៌មានផ្ទាល់ខ្លួន

ព័ត៌មានផ្ទាល់ខ្លួនដែលអ្នកផ្តល់នៅពេលដាក់ពាក្យប្រឡង ឬនៅមណ្ឌលប្រឡងនឹងត្រូវប្រើប្រាស់សម្រាប់គោលបំណងនៃការប្រឡង ការចេញវិញ្ញាបនបត្របញ្ជាក់ការប្រលងជាប់ និងពិចារណាលើប្រព័ន្ធពលករជំនាញ ដោយអនុលោមតាមបទប្បញ្ញត្តិការពារព័ត៌មានផ្ទាល់ខ្លួនរបស់សមាគមថែទាំអគារជប៉ុន។ សូមចំណាំថា ព័ត៌មានផ្ទាល់ខ្លួនអាចត្រូវបានផ្តល់ជូនដល់ទីភ្នាក់ងាររដ្ឋាភិបាលក្នុងប្រទេសជប៉ុន ឬប្រទេសកំណើតរបស់អ្នកដែលធ្វើការប្រឡង។

### - តំណភ្ជាប់ដែលពាក់ព័ន្ធ

សមាគមថែទាំអគារជប៉ុន

សំណួរទូទៅអំពីរយៈពេលនៃការកក់ការ ប្រឡង

ដំណើរការ នៅមណ្ឌលប្រឡងនៅថ្ងៃប្រឡង

### - ការសាកសួរព័ត៌មាន

សូមចំណាំថាកន្លែងសាកសួរព័ត៌មាន នឹងប្រែប្រួលអាស្រ័យលើខ្លឹមសារនៃការសាកសួរព័ត៌មានរបស់អ្នក។

| ខ្លឹមសារនៃការសារសួរព័ត៌មាន | កន្លែងសាកសួរព័ត៌មាន |
|---|---|
| ● ទាក់ទងនឹងការចុះឈ្មោះគណនី វិធីសាស្រ្តកក់ និងអ៊ីមែលជូនដំណឹងអំពីការបញ្ចប់ការកក់<br><br>● ទាក់ទងនឹងឯកសារបញ្ជាក់សាម៉ីខ្លួន<br>● ទាក់ទងនឹងការផ្លាស់ប្តូរឈ្មោះបន្ទាប់ពីចុះឈ្មោះគណនីហើយ<br>● ទាក់ទងនឹងស្ថានភាពទំនេរនៃកន្លែងប្រឡង(មជ្ឈមណ្ឌលប្រឡង) | សេវាកម្មអតិថិជន **Pearson VUE**<br><br>https://www.pearsonvue.com/us/en/test-takers/customer-service/email.html |
| ● ទាក់ទងនឹងខ្លឹមសារនៃការប្រឡង<br>● ទាក់ទងនឹងលក្ខខណ្ឌនិង សិទ្ធិនៃការប្រឡង<br><br>● ទាក់ទងនឹងលទ្ធផលនៃការប្រឡង<br>● ទាក់ទងនឹងការចេញវិញ្ញាបនបត្រប្រឡងជាប់ | សមាគមថែទាំអគារជប៉ុន<br><br>**E-mail:** tokuteiginou@j-bma.or.jp |